# ការសំភាសន៍របស់លោកពូលី ថេង

កៈ អ្នកសំភាស៍គេ សួន សុខលី ខៈ អ្នកដែលត្រូវបានគេសំភាស៍ លី ថេង

កៈ
ចឹងជាដំបូងខ្ញុំសូមថ្លែងអំណរគុណដល់លោកពូដែលអនុញ្ញាតអោយខ្ញុំធ្វើការសំភាស៍នូវជីវប្រវិត្តរបស់លោកពូ ហើយការសំភាស៍នេះគឺធ្វើឡើងដោយសារតែសលកវិទ្យាល័យ BYU. ហើយដោយសាតែសកលវិទ្យាល័យនិងចង់ថែរក្សាប្រវិត្តជីដូនជីតារបស់លោកពូហើយទុកអោយកូនចៅជំនាន់ក្រោយគាត់មើល ហើយនិងស្តាប់។
ហើយបន្ទាប់ពីការសំភាស៍នេះរួចហើយខ្ញុំអាចសុំដាក់ជីវប្រវិត្តរបស់ពូមួយនេះនៅក្នុងប្រព័ន្ធផ្សព្វផ្សាយមួយដែលមានឈ្មោះថា WWW. Cambodianoralhistories.byu.edu បានដែលទេលោកពូ?

ខៈ បាទ។

កៈ ចាហើយខ្ញុំជាអ្នកសំភាស៍លោកពូមានឈ្មោះថា សួន សុខលី ហើយការសំភាស៍នេះឡើងនៅថ្ងៃទី៣១ ខែ០១ ឆ្នាំ២០១៨។ ហើយការសំភាស៍នេះគឺធ្វើឡើងដែលមានទីតាំងនៅភូមិបួន ខ័ណ្ឌចំការមន រាជធានីភ្នំពេញ និងសង្កាត់ផ្សារដើមថ្កូវ។

កៈ ហើយខ្ញុំចង់សួរថាតើលោកពូមានឈ្មោះពេញនិងនាមត្រកូនអី មានឈ្មោះអីដែលលោកពូ?

ខៈ ខ្ញុំឈ្មោះ ថេង។

កៈ ឈ្មោះថេង ចុះត្រកូល?

ខៈ ត្រកូលឈ្មោះ លី។

កៈ លី ថេង?

ខៈ លី ថេង បាទ។

កៈ ចាហើយឈ្មោះរបស់លោកពូនិងត្រូវតាមអតសញ្ញាណប័ណ្ណរបស់លោកពូដែលទេពូ?

ខៈ បាទខ្ញុំអើពីបាកឆ្លើយទៀតនិងណា។

ក៖ ចង់សួរថាត្រូវតាមអតសញ្ញានប័ណ្ណអត់?

ខ៖ អរអតសញ្ញានប័ណ្ណអី?

ក៖ ចា

ខ៖ ខ្ញុំមានតាស។

ក៖ ចាតែឈ្មោះលោកពូត្រូវតាមនិងមែនទេលោកពូ?

ខ៖ បាទតាមឈ្មោះនិងហើយ។

ក៖ ចាហើយខ្ញុំចង់សួរលោកពូថាលោកពូមានឈ្មោះហៅក្រៅដែលឬទេលោកពូ?

ខ៖ ហៅក្រៅ ឈ្មោះគេហៅតែ លី ថេងៗនិង ហើយម្ដាយខ្ញុំឈ្មោះកិន។

ក៖ ចាហើយចឹងចង់សួរលោកពូថាតើអើលោកពូមានអាយុប៉ុនន្មានហើយឆ្នាំនេះ?

ខ៖ ខ្ញុំមានអាយុ សែសិបប្រាំបីរ ជិតអើ សែសិបប្រាំបួន។

ក៖ ចាចឹងសែសិបប្រាំបីរជិតសែសិបប្រាំបួន?

ខ៖ បាទ។

ក៖ ចុះលោកពូកើតនៅឆ្នាំណាខែណាដែលលោកពូ?

ខ៖ អើខ្ញុំអត់គិតអារឿងឆ្នាំណាទេ ដឹងតែអាយុសែសិបប្រាំបួនតែម្ដង និងហើយ។

ក៖ ចាចុះលោកពូអាចប្រហែលតិចមើលថាឆ្នាំមួយពាន់ប្រាំបួនរយប៉ុន្មានអី?

ខ៖ ខ្ញុំអត់ចេះផង។

ក៖ ហាហា អត់ចេះអីអាចប្រហែលណា មុនពពតទេលោកពូ?

ខ៖ អរពពតនៅជំនាន់ពពត។

ក៖ ចាចឹងចង់សួរលោកពូទៀតថាអើ អើលោកពូកើតនៅឆ្នាំខ្មែរណា ដូចជាឆ្នាំជូត ឆ្នាំកុលអីណា?

ខ៖ ខ្ញុំអត់ដឹងទេ អត់សឹងដឹងដែល ខ្ញុំដឹងតែធំឡើងខ្ញុំធ្វើស្រែ ធ្វើទារហាន។

កៈ ចា។

ខៈ ខ្ញុំអត់ដឹងថាខ្ញុំអាយុប៉ុនន្មានអីប៉ុនន្មានផង ប៉ុនន្តែឪពុកខ្ញុំប្រាប់ថា ឯងឆ្នាំកុល អរមែនទេ ឆ្នាំរការ។

កៈ ចាមានឆ្នាំរការ។

ខៈ បាទនិងហើយ។

កៈ ហើយអាឡូវខ្ញុំចង់សួរលោកពូថាលោកពូកើតនៅកន្លែណា? ស្រុកណា ខេត្តណានិងឃុំណាដែល?

ខៈ ស្រុកខ្ញុំនៅឃុំអើស្វាយជ្រុំណា អរមែនទេស្វាយរការ អត់ទេស្វាយរការនិងស្រុកប្រពន្ធខ្ញុំ ខ្ញុំនៅបារាយណ៏។

កៈ បារាយណ៏នៅខេត្តណា?

ខៈ បារាយណ៏ខេត្តកំពង់ចាម ស្រុកព្រៃកសធ្វរ ខេត្តកំពង់ចាម និងហើយ។

កៈ ហើយអើខ្ញុំចង់សួរលោកពូទៀតថា តើលោកពូមានបងប្អូនចំនួនប៉ុនន្មាននាក់ដែល?

ខៈ អរខ្ញុំមានបងប្អូនដប់បីរនាក់ ងាប់អស់បីរនាក់ហើយ នៅសល់ដប់នាក់។

កៈ អរចាហើយខ្ញុំអាច តើលោកពូជាកូនទីប៉ុនន្មានដែល?

ខៈ ខ្ញុំមើលរាប់សិន មួយ ពីរ បីរ បួន ខ្ញុំ បួននិងខ្ញុំនៅប្អូនគេទេបួននាក់និង។

កៈ ចាចឹងលោកពូជាកូនទីបួន ចឹងលោកពូអាចរៀបរាប់ឈ្មោះពីកូនទីមួយរហូតដល់កូនទាំងដប់បីរនាក់និងបានដែលទេ លោកពូ?

ខៈ បាទ។

កៈ ថាមានឈ្មោះអីគេខ្លះ?

ខៈ បងរុន បងរូ បងរុនអើនិង បងច័ន្ទហើយខ្ញុំ នៅមានប្អូនបីរនាក់ទៀត។

កៈ ចាឈ្មោះអីពូ?

ខ៖ អរមានច្រើនណាស់ មីមួយនេះមានឈ្មោះថាមីការថន ការថុន ការធឿន តែប៉ុននិងសរុបទៅប្រាំពីរនាក់។

ក៖ ចាហើយចុះនាក់ដែលស្លាប់ហើយ?

ខ៖ អរអាឡិតនេះមួយ សរុបទៅប្រាំបីរនាក់។

ក៖ ចុះអ្នកដែលស្លាប់និងឈ្មោះអីដែលទៅលោកពូ?

ខ៖ បងខ្ញុំអត់ស្លាប់ទេ។

ក៖ អត់ទេបងប្អូនពូសរុបទាំងអស់មានដប់បីរនាក់មែនទេលោកពូ?

ខ៖ និងហើយ អ្នកស្លាប់និងកើតមកស្លាប់ ឆ្លងទន្លេបានប៉ុនន្មានខែនិងគាត់ស្លាប់ទៅនិងហើយ។

ក៖ ចាហើយអើខ្ញុំចង់សួរលោកពូទៀតថាតើលោកពូចង់ចាំសាច់រឿងអីគេខ្លះកាលពីលោកពូនៅក្មេងជាមួយនិងបងប្អូនរបស់លោកពូណា?

ខ៖ អើជំនាន់ខ្ញុំនៅពីរក្មេងនិងគ្មានទៅខុសអីទេខ្ញុំមិនទៅធ្វើអីផង ខ្ញុំដើរទៅធ្វើការ ជីកដីលីម៉ុងអីចឹងទៅ។

ក៖ ចាចង់និយាយថាលោកពូធ្លាប់រត់លេង ប្រលែងលេងជាមួយបងប្អូនលោកពូណាធ្លាប់ធ្វើអីគេខ្លះជាមួយពួកគាត់?

ខ៖ អើបងប្អូនខ្ញុំនុះនាំគ្នាទៅធ្វើចំការឆ្ងាយៗណាស់ ធ្វើចំការធំៗ ខ្លះទៅស៊ីឈ្នួលគេខ្លះទៅធ្វើសំណង់ បែកគ្នាអស់ហើយបងប្អូនខ្ញុំ។

ក៖ ចា។

ខ៖ ខ្ញុំនៅតែពីរនាក់ប្ដីប្រពន្ធនិងដូចកំព្រារកំព្រុកចឹង។

ក៖ ចាចុះអាឡូវពួកគាត់រស់នៅកន្លែងណាដែលលោកពូ?

ខ៖ ខ្ញុំរស់នៅទីនិង។

ក៖ ចាបងប្អូនលោកពូ?

ខ៖ បងប្អូនអើគេរស់នៅឆ្ងាយៗណាស់ មួយនៅនេះ មួយនៅឯនុះ។

ក៖ ទៅនៅដល់ណាលោកពូរៀបរាប់មើល នេះនោះនិង?

ខ៖ អរច្រើនណាស់ នៅព្រៃណប់ផង ស្វាយរៀងអីណានីនុះ ខ្ញុំនៅស្វាយរៀង។ ហើយបងប្អូនខ្ញុំនៅនិងបីរបួននាក់ឯនុះ។

ក៖ ចាហើយអ្នកផ្សេងទៀត?

ខ៖ មួយទៀតនៅនេះនៅកំពង់ចចាម អត់តែប្អូនខ្ញុំមួយនិងនៅនេះ នៅកំពង់ចាមខេត្តព្រៃពោតិ៍និង។

ក៖ ខេត្តព្រៃពោតិ៍ចា។ អរគុណលោកពូហើយខ្ញុំចង់សួរលោកពូថាឪពុកម្តាយរបស់លោកពូមានឈ្មោះអីគេដែល?

ខ៖ ឪពុកម្តាយខ្ញុំមែន?

ក៖ ចា។

ខ៖ លីគិន។

ក៖ លីគិន។

ខ៖ បាទ។

ក៖ ចុះត្រកូល?

ខ៖ ត្រកូល អើតាប៉ាត់។

ក៖ ប៉ាត់ លីគិន ហើយម្តាយ?

ខ៖ លីគិននិងម្តាយខ្ញុំនិង។

ក៖ ចឹងម្តាយឈ្មោះលីគិននិង?

ខ៖ បាទនិងហើយ ហាហា។

ក៖ ចាហាហា ហើយចុះឪពុកវីញ?

ខ៖ ឪពុកមែន?

កៈ ចាឪពុកឈ្មោះអី?

ខៈ ឪពុកខ្ញុំឈ្មោះលី។

កៈ ហើយទាំងឪពុកនិងម្ដាយឈ្មោះលីដូចគ្នា?

ខៈ អត់ទេចង់និយាយថាទាំងឈ្មោះម្ដាយនិងឪពុកនិងឈ្មោះ លីគីន។

កៈ អរចឹងពូចង់មានន័យថាឪពុកឈ្មោះគិន ម្ដាយឈ្មោះលី?

ខៈ បាទ។

កៈ ចាហើយចុះនាមត្រកូលពួកគាត់និងលោកពូចាំបានទេ?

ខៈ នាមត្រកូលគាត់ អើនិយាយពីឈ្មោះគាត់មែន?

កៈ ចាត្រកូលណា?

ខៈ អើបើត្រកូលឈ្មោះ តាប៉ាត បើឈ្មោះគត់អីមិនដឹងទេ ហាហា។

កៈ ចាចុះលោកពូចាំអំពីអាយុរបស់ពួកគាត់ថា ពួកគាត់មានអាយុប៉ុន្មានទេ?

ខៈ អើតាប៉ាតអី?

កៈ ចា។

ខៈ អើតាប៉ាត អាយុចិតសិប កៅសិប ឬក៏មួយរយឯនុះ។

កៈ អត់ទេអាយុឪពុកម្ដាយរបស់លោកពូ?

ខៈ អរឪពុកម្ដាយខ្ញុំ ខ្ញុំមិនចាំទេ អត់ជាំសោះ ជីដូនជីតាខ្ញុំអីក៏មិនចាំដែល។

កៈ ឆ្នាំខ្មែរអីនិងអត់ចាំដែល?

ខៈ និងហើយអត់ចាំទេ ហាហា។

កៈ ហាហា ហើយចុះពួកគាត់នៅរស់ដល់សព្វថ្ងៃឬមួយក៏ស្លាប់អស់ហើយលោកពូ?

ខៈ ពួកគាត់ងាប់បាត់អស់ហើយ គឺស្លាប់ទាំងអស់។

កៈ ចាពួកគាត់ស្លាប់នៅសម័យណាដែលលោកពូ?

ខ៖ អើគាត់ស្លាប់នៅជំនាន់អាពពត
កាលនិងគាត់រត់ពីនាក់ខ្ញុំនិងគេដេញបាញ់រត់ចូលក្នុងព្រៃឯនុះ។
ខ្ញុំតូចចិត្តនិងរឿងគេចាប់បាន ឪពុកខ្ញុំរត់ទៅរកអង្ករយកមកដាំបាយចែកគ្នាហូម
នាំគ្នាអង្គុយជំរងជួគ្នាចឹង ខ្ញុំតូចចិត្តរឿងខ្ញុំណាស់។

ក៖ ចាចឹងមានន័យថាឪពុករបស់លោកពូនិងគាត់ស្លាប់នៅជំនាន់ពពត?

ខ៖ និងហើយ។

ក៖ ចាហើយលោកពូអាចរៀបរាប់អំពីប្រវិត្តនិង
អំពីអើអ្វីខ្លះដែលកើតឡើងនៅក្នុងជីវិតរបស់លោកពូនៅសម័យពពតនិងអោយខ្ញុំស្តាប់បន្តិចបានទេពូ?

ខ៖ នៅជំនាន់ពពតមែន?

ក៖ ចាលោកពូធ្វើអីគេខ្លះនៅជំនាន់និង?

ខ៖ អើខ្ញុំពេលនិងកុំពង់តែរត់ទៅហើយ។

ក៖ ចាកាលនិងអាយុប្រហែលប៉ុនន្នានដែលលោកពូ?

ខ៖ ពេលនិងឪពុកខ្ញុំអាយុច្រើនដែលនិង។

ក៖ អតើទេចង់និយាយពីលោកពូណា? ពូកាលនិអាយុប៉ុន្នាន?

ខ៖ អើមិនដឹងអាយុប៉ុន្នានទេ។

ក៖ ចាហើយមេចទៀតពូ?

ខ៖ អើឪពុកខ្ញុំនិងគ្នានទៅដឹងរឿងអាយុគាត់អីប៉ុន្នានទេ ខ្ញុំអត់ដឹងផង គាត់ប្រាប់ថា
ឯងឆ្នាំរកាតែប៉ុននិង។

ក៖ ចាហើយកាលនៅជនាន់ពពតនិងមេចដែលពូជីវិតពូណា?

ខ៖ អរខ្ញុំប្រឹងរត់តាមកង់អាទៀសឯនុះ នៅភូមិខ្ញុំមានកូនខ្ចីល្ងាចនិង
គេយកដាក់នៅអារទេះនិងយប់ឡើងគេយកទៅ ហើយយកទៅនិងទៅវៃចោល
សុទ្ធតែដងរែកនេះ ខ្ញុំគ្រាន់តែឃើញប៉ុននិងទេ តែបងខ្ញុំនៅធ្វើការនៅជំនាន់ពពតនិងណា

បងខ្ញុំគាត់រត់ហើយអាពពតវាដេញបាញ់តែម្តង តែប៉ុននិង។ ហើយឪពុកខ្ញុំក៏គាត់មកដាស់ខ្ញុំ ពេលគាត់មកដដាស់ខ្ញុំ រួចគាត់ប្រាប់ឪពុកខ្ញុំថា ឪៗពពតមកដេញបាញ់ខ្ញុំហើយ។ ហើយបើស្រីៗអត់សំលាប់ទេ វាអោយមកផ្ទះវិញ បងខ្ញុំនិងគាត់រត់មកតាស់កុំអីនិងងាប់បាត់។

កៈ ចាហើយកាលនៅក្នុងជំនាន់ពពតនិងពូមានទៅសែងដី សែងអីទេពូ?

ខៈ ខ្ញុំអត់សែងទេ មានតែទៅសែងអាច៍ក្របីរ កាលនិងខ្ញុំនៅតូចៗដែល នៅកំពស់ៗនេះ សែងអាច៍ក្របីរអោយយកទៅដាក់នៅក្នុងស្រែ ហើយនិងដាកើនៅកន្លែងជែតដីស្តេចកនពីដើមនុះ។

កៈ ចាហើយចឹងខ្ញុំចង់សួលោកពូទៀតថាតើអើនៅពីក្មេងនិងតើលោកពូរស់នៅកន្លែងណាដែល?

ខៈ ខ្ញុំរស់នៅកំពង់ចាម។

កៈ រស់នៅកំពង់ចាម។ ហើយពេលជំនាន់ពពតនិងលោកពូរស់នៅកំពង់ដែល?

ខៈ បាទខ្ញុំនៅខាងប្រែជំបូក ព្រៃកពោតិអីនិង នៅស្រុកបារាយណ៏។

កៈ ពេលអាពពតចូលនិងពូរស់នៅខេត្តកំពង់ចាមដែល?

ខៈ និងហើយ បើអាពពតនិងវាដេញបាញ់ខ្ញុំរត់ផ្អើលភូមិឯនុះ ហាហា។

កៈ ចាហើយលោកពូមានបានរត់អត់។

ខៈ ខ្ញុំរត់តាស ហាហា ខ្ញុំរត់ចោលឪពុកខ្ញុំ ឪពុកខ្ញុំមកបង់សំណាញ់ត្រីអោយខ្ញុំយកហូម គាត់ថាអោយខ្ញុំនិងនៅចាំនៅកន្លែងនិងសិនចាំប៉ាមកយកកូនឯង កូនបីរនាក់បួននាក់ហើយគាត់នាំកូនរត់បិទទ្វាផ្ទះចោល ម្តាយខ្ញុំនៅសល់មាសប្រាំជី ហើយខ្ញុំនៅពីក្មេងមិនដឹង លែងខ្ញុំយកអាខ្សែករនិងទៅប្រដាច់ចោល ហើយអាពពតនិងមកអោយខ្ញុំវៃផ្លែយកទៅស៊ី ហាហា អរគុណតែប៉ុននិងទេ។

កៈ ចាអរគុណពូ។ ហើយខ្ញុំចង់សួលោកពូទៀតថា តើលោកពូចាំថាឪពុកម្តាយលោកពូនិងស្លាប់នៅជំនាន់ពពតទាំងពីរនាក់និងឬក៏យ៉ាងមេច?

ខៈ បាទពួកគត់ស្លាប់នៅជំនាន់ពពត។

កៈ ចាហើយបន្ទប់ពីបែកចេញពីជំនាន់ពពតមក
នៅពេលដែលគេរំដោះនិងពូទៅរស់នៅណាដែលឬក៏យ៉ាងមេច?

ខៈ នៅពេលដាច់និង ខ្ញុំមកដាច់នៅភ្នំពេញទេ
រួចទៅបានខ្ញុំជួបប្រពន្ធខ្ញុំនិងក៏ខ្ញុំយកប្រពន្ធតែម្តងទៅ។

កៈ ចាហើយខ្ញុំចង់សួរលោកពូទៀតថា
តើឪពុករបស់ណាតើគាត់ធ្វើអ្វីខ្លះសំរាប់ចិញ្ចឹមជីវិតរបស់គាត់?

ខៈ មានតែខ្ញុំទេពេលគាត់ស្លាប់ហើយបែកបងប្អូនទាំងអស់ ខ្ញុំដើររកស៊ីដោយសារប្រពន្ធ
នៅពេលខ្ញុំបានប្រពន្ធមកគឺខ្ញុំខំរកស៊ីចិញ្ចឹមប្រពន្ធរហូត។

កៈ ចាតើលោកពូចាំថាឪពុករបស់លោកពូ
ប៉ារបស់លោកពូនិងតើគាត់រកស៊ីអីសំរាប់ចិញ្ចឹមកូនប្រពន្ធណាលោកពូមានចាំទេ?

ខៈ គាត់ចិញ្ចឹមគឺគាត់រកត្រី និងធ្វើស្រែ។

កៈ អរចា ហើយចុះឪពុករបស់លោកពូនិងតើគាត់ជាមនុស្សបែបណាដែលសំរាប់លោកពូ?
ដូចជាស្លូត កាច់អីណា?

ខៈ ឪពុកខ្ញុំគាត់មិនកាច់ទេ គាត់ស្លូតដែលនិង
ប៉ុន្តែប្រពន្ធផឹកស្រារទៅរួចគាត់រករឿងឪពុកខ្ញុំទៅ ឪពុកខ្ញុំគាត់កប់ក្បាលទៅ
បាទប៉ុននិងបានហើយអរគុណណាស់។

កៈ ចាហើយខ្ញុំចង់សួរទៀតថាតើម្តាយរបស់លោកពូណា
តើគាត់រកស៊ីអីសំរាបចិញ្ចឹមជីវិតដែល? ដូចជាគាត់រកស៊ីអីម្តាយរបស់ពូណា?

ខៈ ឪពុកខ្ញុំធ្វើស្រែ។

កៈ ម្តាយ?

ខៈ ម្តាយខ្ញុំធ្វើស្រែដែល។

កៈ គាត់ធ្វើស្រែដែល?

ខ៖ បាទធ្វើស្រូវឡើងក្រលាស់ទ្រណាប់ ដល់តែពេលមីងខ្ញុំនិងគាត់ដូរស្រែទៅ គាត់ក៏អោយស្រូវអាខាងលើនិងបីរថាង ហើយគាត់ទៅយកអាខាងនេះវិញ និងតែប៉ុននិងទេ។

ក៖ ចាហើយអើខ្ញុំចង់សួរលោកពូទៀតថា តើម្ដាយរបស់លោកពូតើគាត់គឺជាមនុស្សបែបណាដែលសំរាប់លោកពូណា?

ខ៖ អរគាត់គឺជាមនុស្សរឹងក្បាល។

ក៖ រឹង?

ខ៖ បាទ។

ក៖ តែខ្ញុំចង់សួរថាម្ដាយរបស់លោកពូតើគាត់គឺជាមនុស្សកាច់ ឬក៏ស្លូតសំរាប់លោកពូណា?

ខ៖ អើម្ដាយខ្ញុំនិងអី ម្ដាយខ្ញុំគាត់កាច់ប៉ុន្តែគាត់ហូមស្រារតែខឹងរករឿងហើយ ជូនកាលទៅហូមរួចហើយអស់ហើយ ហាហា។

ក៖ ចាហើយអើខ្ញុំចង់សួរលោកពូទៀតថា តើលោកពូចងចាំអីខ្លះអំពីឪពុកម្ដាយរបស់លោកពូនៅពេលដែលលោកពូនៅក្មេងណា?

ខ៖ អរពេលខ្ញុំនៅពីក្មេងខ្ញុំកើតបួសកើតអី។

ក៖ អត់ទេចង់និយាយពីឪពុកម្ដាយរបស់លោកពូថាគាត់ធ្វើអី?

ខ៖ គាត់នឹកឃើញអាបងនេះធ្វើទារហាន ធ្វើទារហានគេបាញ់គាត់រត់មកផ្ទះវិញតាមផ្លូវព្រៃកហូណារួចក៏ឈ្លក់ទឹក ដល់ហើយគាត់ក៏មកស្លរស៊ី ស្លរត្រកួននិងត្រីអាំងហើយនិងប្រហុកយើងនិងកញ្ច្រាទៅរួចគេក៏បាញ់មក នៅពេលល្ងាចម៉ោងប្រាំនិងគេបាញ់មក រួចគាត់ក៏រត់រួចទៅគាត់ថាឆ្លប់មកហើយឆ្លប់ តែប៉ុននិង។

ក៖ ចាអរគុណច្រើនលោកពូ ហើយខ្ញុំចង់សួរលោកពូទៀតថា តើលោកពូនៅចាំឈ្មោះជីដូនជីតារបស់លោកពូណា ថាពួកគាត់មានឈ្មោះអីខាងម្ដាយ តាយាយនិងណា?

ខ៖ ខាងម្ដាយអី?

ក៖ ចា។

ខ៖ អើឈ្មោះសួង ហើយនិងតាប៉ាត់។

ក៖ យាយឈ្មោះសួង ហើយតាឈ្មោះ តាប៉ាត់។ ហើយចុះខាងឪពុកវិញ?

ខ៖ ខាងឪពុកខាង។

ក៖ យាយតាណា?

ខ៖ យាយតាខាងនេះ យាយទៅខ្ញុំអត់ស្គាល់ដែលនិង
គាត់ស្លាប់អស់ហើយខ្ញុំកើតអត់ទាន់ផង បាទ។

ក៖ ចាហើយចឹងខ្ញុំចង់សួរលោកពូទៀតថា
លោកពូមានដឹងថាយាយតារបស់លោកពូនិងកើតនៅឆ្នាំណាខែណាអត់?

ខ៖ អត់ដឹងផង ខ្ញុំមិនដឹងខែឆ្នាំរបស់គាត់ទេ។

ក៖ ចាចឹងគាត់ស្លាប់នៅពេលណា?

ខ៖ និយាយពេលគាត់ស្លាប់?

ក៖ ចា។

ខ៖ អឺពួកគាត់ស្លាប់នៅជំនាន់មុនអាពពត ហើយឪនិងក៏ស្លាប់មុនអាពពតនិងដែល
អរមិនមែនទេឪពុកខ្ញុំនិងស្លាប់ក្រោយអាពពតទេ។ គាត់ស្លាប់ក្រោយអាពពតទេ។

ក៖ ចាហើយខ្ញុំចង់សួរលោកពូទៀតថា
តើក្រុមគ្រួសារសព្វថ្ងៃនិងបងប្អូនដែលលោកពូមាននិងណាពួកគាត់រស់នៅខេត្ត
ចឹងលោកពូមានសាច់ញាតិដែលរស់នៅអើប្រទេសក្រៅទេ?

ខ៖ នៅប្រទេសក្រៅមែន?

ក៖ ចាមានទេ?

ខ៖ មានបងប្អូនមួយ។

ក៖ គាត់រស់នៅប្រទេសអីដែល?

ខ៖ នៅចិន។

ក៖ នៅចិន?

ខ៖ និងហើយ។

ក៖ គាត់បានប្តីទៅនៅនិងមែនពូ?

ខ៖ អានិងខ្ញុំ អែសប្តីពីរហើយប្តី ហើយក៏លែងលេះគ្នារ រួចវារត់ទៅមានកូនបីរបួនហើយ
ខ្ញុំយកកូនពីរវាមួយទុកនៅនិងខ្លួនខ្ញុំ
រួចតាំងតែពីតូចមកខ្ញុំយកមកចិញ្ចឹមរស់ទល់អាឡូវនិង។

ក៖ ចាហើយចឹងខ្ញុំចង់សួរលោកពូទៀតថាតើប្រពន្ធរបស់លោកពូមានឈ្មោះអីដែល?

ខ៖ សៀងណា។

ក៖ ប្រពន្ធលោកពូណា ទាំងត្រកូនមានឈ្មោះអី?

ខ៖ និងហើយឈ្មោះ សៀង ណា និង។

ក៖ ចឹងសៀងណា?

ខ៖ នាងណា ហៅតែ នាងណាទៅបានហើយ។

ក៖ អរហើយខ្ញុំចង់សួរថាលោកពូរៀបអាពាហ៍ពិពាហ៍នៅឆ្នាំណាខែណាដែល?

ខ៖ អរនៅខែនេះមើល អើ។

ក៖ នៅខែបួន ចុះឆ្នាំ?

ខ៖ មើលពេលដែលខ្ញុំបានប្រពន្ធខ្ញុំនិងនៅឆ្នាំមួយពាន់ប្រាំបួនរយកៅសិបបួន
និងហើយគឺនៅកៅបួនខ្ញុំធ្វើទាហានបានមួយឆ្នាំ
ខ្ញុំក៏រត់មកភ្នំពេញវិញហើយបានចូលធ្វើការលើកដែកជាមួយពួកកម្មករនិងអាឡូវខ្ញុំឈប់ធ្វើ
ហើយតែប៉ុននិង។

កៈ ចាហើយអើខ្ញុំចង់សួរលោកពូថា
កាលលោកពូរៀបអាពាហ៍ពិពាហ៍និងដោយឪពុកម្តាយជាអ្នករៀបចំអោយឬក៏រៀបដោយចិត្តឯងដែលលោកពូ?

ខៈ ម្តាយខ្ញុំអូរច្រើនណាស់

កៈ
ចង់និយាយថាលោកពូរៀបការជាមួយប្រពន្ធពូនិណាដោយចិត្តឯងឬក៏ម្តាយជាអ្នករៀបចាំអោយ?